វិទ្យាស្ថាន
បណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា

ក្រុមប្រឹក្សា
ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម
និងជនបទ

IFPRI
វិទ្យាស្ថាន
ស្រាវជ្រាវគោលនយោបាយ
ស្បៀងអន្តរជាតិ

# អភិបាលកិច្ចធនធានធម្មជាតិ និងសន្តិសុខស្បៀងនៅកម្ពុជា

## ឯកសារពិភាក្សាគោលនយោបាយ



បណ្ឌិត ប្លេក រាតណ័រ អ្នកស្រាវជ្រាវជាន់ខ្ពស់
នៃវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ
វ៉ាស៊ីនតោន ឌីស៊ី

ខែមីនា ឆ្នាំ២០១១

របាយការណ៍ពិសេស លេខ ៨

ឧបត្ថម្ភដោយ USAID FROM THE AMERICAN PEOPLE

# អភិបាលកិច្ចធនធានធម្មជាតិ និងសន្តិសុខស្បៀងនៅកម្ពុជា

## ឯកសារពិភាក្សាគោលនយោបាយ

រៀបរៀងសម្រាប់
កិច្ចប្រជុំតុមូលស្តីពីសន្តិសុខស្បៀង
និងគោលនយោបាយកសិកម្មកម្ពុជា
ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០ នៅសណ្ឋាគារភ្នំពេញ
CDRI ក្នុងកិច្ចសហការជាដៃគូជាមួយ CARD និង IFPRI
ឧបត្ថម្ភដោយ USAID


ដោយ
បណ្ឌិត Blake D. Ratner អ្នកស្រាវជ្រាវជាន់ខ្ពស់
នៃវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយស្បៀងអន្តរជាតិ
វ៉ាស៊ីនតោន ឌីស៊ី

**បេសកកម្ម វបសអ**

ក្នុងលក្ខណៈជា វិទ្យាស្ថានកម្ពុជាឯករាជ្យផ្នែកស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មរួមចំណែកដល់ការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព និងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។

វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹងនិងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

© **រក្សាសិទ្ធិឆ្នាំ២០១១ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា** (**វបសអ**)

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

## អភិបាលកិច្ចធនធានធម្មជាតិ និងសន្តិសុខស្បៀងនៅកម្ពុជា

ឯកសារពិភាក្សាគោលនយោបាយ

ខែមីនា ឆ្នាំ២០១១

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣
ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@wicam.com.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ទា សាវរា

## មាតិកា

សារតារះ ហេតុអ្វីបានជាអភិបាលកិច្ចធនធានធម្មជាតិមានសារៈសំខាន់........7

ការសម្រួចអាទិភាពះ ជម្រើសដែលមានលក្ខណៈជាយុទ្ធសាស្ត្រចំពោះអភិបាលកិច្ចធនធានធម្មជាតិ........8

ការលើកម្ពស់ប្រសិទ្ធភាពះ អភិវឌ្ឍន៍ស្ថាប័ននិងកំណែទម្រង់អភិបាលកិច្ច........10

សេចក្តីសន្និដ្ឋាន........13

## សាវតារៈ ហេតុអ្វីបានជាអភិបាលកិច្ចធនធានធម្មជាតិមានសារៈសំខាន់

ប្រទេសកម្ពុជា មានកំណើនសេដ្ឋកិច្ចឆាប់រហ័សអស់រយៈពេលមួយទសវត្សរ៍រហូតដល់ឆ្នាំ២០០៧ នាអំឡុងពេលនេះ កម្ពុជាស្ថិតក្នុងចំណោមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចរីកចម្រើនឆាប់រហ័សមួយចំនួននៅលើពិភពលោក ។ ក្នុងអំឡុងពេលដូចគ្នា គេឃើញមានវឌ្ឍនភាពគួរឱ្យកត់សំគាល់ ចំពោះការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់សន្តិសុខស្បៀង ។ ទោះបីប្រទេសកម្ពុជាងើបឡើងវិញពីវិបត្តិហិរញ្ញវត្ថុសាកលក្តី និន្នាការកំណើនកាលពីពេលថ្មីៗ “មិនទំនងជាអាចមាននិរន្តរភាពដោយខ្លួនឯងបានឡើយ” (World Bank and IFC 2009: xi) ព្រោះថា ប្រទេសកម្ពុជាពឹងផ្អែកលើវិស័យមួយចំនួនតូច ហើយត្រូវបានជម្រុញដោយព្រឹត្តិការណ៍ដែលគេមិនអាចអនុវត្តសាជាថ្មីឡើងវិញបាន រួមមាន ការងើបចេញពីសង្គ្រាម ការកសាងឡើងវិញនូវទំនាក់ទំនងសេដ្ឋកិច្ចក្នុងតំបន់ និងទំនាក់ទំនងសេដ្ឋកិច្ចពិភពលោក ការផ្តល់ជំនួយអភិវឌ្ឍន៍ និងចំណុចចាប់ផ្តើមដែលមានកំរិតទាបជាខ្លាំង ។ ជាងនេះទៀតនោះ អំឡុងពេលដែលមានកំណើនឆាប់រហ័សនេះពឹងផ្អែកជាខ្លាំងលើការធ្លាក់ចុះនូវមូលដ្ឋានសម្បត្តិធនធានធម្មជាតិ ។

ការសម្លឹងមកខាងក្រោយច្បាស់ណាស់ថា គោលនយោបាយល្អ និងកិច្ចប្រឹងប្រែងច្រើនបែបច្រើនយ៉ាង ដើម្បីកែលម្អអភិបាលកិច្ចក្នុងវិស័យសេដ្ឋកិច្ចជាក់លាក់ បានបង្ហាញឱ្យឃើញលទ្ធផល ដែលរួមចំណែកដល់កំណើន និងផ្តល់ឱកាសការងារថ្មីៗ ចំពោះប្រជាជនដែលកំពុងកើនឡើង ។ គេឃើញចំណុចនេះច្បាស់បំផុតនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់ ដែលបានផ្តល់អត្ថប្រយោជន៍មិនត្រឹមតែពីកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិ និងគោលនយោបាយនានាដើម្បីលើកកម្ពស់វិនិយោគវិស័យឯកជនប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ផងដែរនោះ គឺពីការអនុវត្តស្តង់ដារការងារអន្តរជាតិ និងកិច្ចព្រមព្រៀងថ្មីៗ ដោយមានការតាមដានពីសំណាក់ភាគីទីបី គឺអង្គការពលកម្មអន្តរជាតិ និងពីក្រុមសង្គមស៊ីវិលឯករាជ្យផងដែរ (World Bank and IFC 2009) ។

ការសម្លឹងឆ្ពោះទៅអនាគត ក៏មានលក្ខណៈច្បាស់លាស់ផងដែរដែលថា ការធ្វើឱ្យមាននិរន្តរភាពកំណើន និងការពង្រីកផលប្រយោជន៍ឱ្យបានកាន់តែពេញលេញ ដល់ប្រជាពលរដ្ឋងាយរងគ្រោះនៅតាមផ្នែកផ្សេងៗ តម្រូវឱ្យមានការប្រឈមមុខជាមួយនឹងហានិភ័យធ្ងន់ធ្ងរមួយចំនួន ។ អំឡុងពេលមានកំណើនកាលពីពេលថ្មីៗ ត្រូវបានកត់សម្គាល់ដោយការកើនឡើង “ឆាប់រហ័សខុសពីធម្មតា” នៃវិសមភាព មិនត្រឹមតែរវាងប្រជាជនជនបទ និងប្រជាជនទីក្រុងប៉ុណ្ណោះទេ ប៉ុន្តែក៏មានវិសមភាពរវាងប្រជាជននៅជនបទផងដែរ (World Bank and IFC 2009) ដោយសារគ្រួសារមួយចំនួនមានលទ្ធភាពទាញយកអត្ថប្រយោជន៍ពីសេដ្ឋកិច្ច ចំណែកអ្នកដទៃទៀត ខ្វះធនធានក្នុងការធ្វើបែបនេះ ហេតុនេះមិនអាចតាមគេឯងទាន់បានឡើយ ។ កង្វះធនធាននេះ គឺជាប្រភពចំបងនៃភាពងាយរងគ្រោះចំពោះគ្រួសារនៅជនបទ (World Bank 2006) ហើយក៏ជាមូលហេតុសំខាន់មួយ បណ្តាលឲ្យភាពក្រីក្រ និងកង្វះអាហារូបត្ថម្ភតែងកើតមានជានិច្ចកាល ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ សុខាភិបាល អប់រំ និងជនបទ ហើយនិងមីក្រូឥណទាន មានសារៈសំខាន់ក្នុងការលើកកម្ពស់ផលបត្រវិនិយោគនៃទ្រព្យសម្បត្តិ (asset portfolio) របស់គ្រួសារដែលមានភាពងាយរងគ្រោះ ប៉ុន្តែតម្រូវការចាំបាច់ និងបន្ទាន់បំផុតនោះ គឺការលើកកម្ពស់ការធានាឱ្យពួកគេមានលទ្ធភាពទទួលបានធនធានធម្មជាតិ ដែលគាំទ្រដល់ការចិញ្ចឹមជីវិតនៅតាមជនបទ ។

ចំពោះប្រជាជននៅជនបទដែលពឹងផ្អែកជាចំបងលើវិស័យកសិកម្ម ល្បឿនឆាប់រហ័សនៃការប្រមូលផ្តុំ ការកាន់កាប់ដីធ្លី សភាពកើតមានទូទៅនៃទំនាស់ដីធ្លី និងបរាជ័យដែលមានលក្ខណៈជាប្រព័ន្ធ ក្នុងការដោះស្រាយទំនាស់នានា (CHRAC 2009) ពិតជាបង្កឱ្យមានកង្វល់ច្រើន ។ ទំនាស់ស្តីពីលទ្ធភាពបានទទួលដីកសិកម្ម ក៏ដូចជា ទំនាស់អំពីលទ្ធភាពបានទទួលធនធានពីសម្បត្តិរួមនៃព្រៃឈើ និងជលផល អាចបង្កើតឱ្យមានអស្ថិរភាពសង្គម និងអំពើហិង្សាទូទៅ (Bannon and Collier 2003) ។ លទ្ធភាពទទួលបានធនធានធម្មជាតិប្រកបដោយសមធម៌ គឺជាធាតុមួយមានសារៈសំខាន់ជាខ្លាំងនៃសំណាញ់សុវត្ថិភាពសង្គម សំរាប់គ្រួសារក្រីក្រនៅជនបទ ពិសេសនៅក្នុងប្រទេសមួយដូចជាប្រទេសកម្ពុជាជាដើម ដែលកម្មវិធីការពារសង្គមផ្លូវការនៅមានភាពខ្វះចន្លោះជាខ្លាំង ហើយធនធានរបស់រដ្ឋក្នុងការផ្តល់មូលនិធិមក

លើចំណុចទាំងអស់នេះ មានកំរិតតិចតួច ។ ប្រាកដណាស់ថា ការធានាលទ្ធភាពឱ្យគ្រួសារក្រីក្របានទទួលធនធានធម្មជាតិ អាចជួយកសាងសមត្ថភាពធន់ទ្រាំរបស់ពួកគេ នៅពេលមានវិបត្តិសេដ្ឋកិច្ច និងនៅពេលមានគ្រោះមហន្តរាយធម្មជាតិ ។ ក្នុងរយៈពេលវែងសមធម៌ចំពោះការកាន់កាប់ដីធ្លីត្រូវបានបង្ហាញថា បានរួមចំណែកយ៉ាងច្រើនចំពោះកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ក្នុងអន្តរកាលពីសេដ្ឋកិច្ចកសិកម្ម ទៅកាន់សេដ្ឋកិច្ចឧស្សាហកម្មទំនើប ដូចករណីនៅប្រទេសជប៉ុន តៃវ៉ាន់ និងកូរ៉េខាងត្បូងជាដើម ។

ការធ្វើឱ្យមាននិរន្តរភាពចំពោះកំណើន ការកាត់បន្ថយភាពក្រីក្រ និងការពង្រឹងសន្តិសុខស្បៀង ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខ ចាំបាច់ត្រូវធ្វើពិពិធកម្មសេដ្ឋកិច្ចជនបទកម្ពុជា និងកែប្រែការចាត់ចែងផ្នែកស្ថាប័ន និងអភិបាលកិច្ចដោយផ្អែកលើមូលដ្ឋានឧត្តមភាពប្រៀបធៀបរបស់កម្ពុជា ដែលសម្បូណ៌ដីធ្លី មានសម្បត្តិធម្មជាតិ ដែលនៅមានគុណភាពខ្ពស់ និងមានពលកម្មក្នុងតម្លៃថោក (World Bank and IFC 2009) ។ រហូតមកដល់ពេលនេះ ការរួមចំណែកភាគច្រើននៃវិស័យធនធានធម្មជាតិចំពោះកំណើន គឺដោយសារការធ្វើអាជីវកម្មផ្អែកលើមូលដ្ឋានទ្រព្យសម្បត្តិ ជាជាងការគ្រប់គ្រងដោយនិរន្តរភាព ។ ធនាគារពិភពលោក និងសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (២០០៩) កំណត់ការកែលម្អលើការគ្រប់គ្រងធនធានធម្មជាតិថាជាអាទិភាពចំបងមួយក្នុងចំណោមអាទិភាពសំខាន់បំផុតបី សំរាប់ធានាឱ្យកំណើនមាននិរន្តរភាព ។

ឈរលើមូលដ្ឋានសារៈសំខាន់ជាចំបងនៃអភិបាលកិច្ចធនធានធម្មជាតិ ចំពោះសន្តិសុខស្បៀង និងអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ តើគោលនយោបាយផ្នែកណាខ្លះ ដែលគួរយកចិត្តទុកដាក់លើការពិភាក្សាផ្នែកគោលនយោបាយ និងការស្រាវជ្រាវផ្អែកលើភស្តុតាង? ផ្អែកពីរបន្ទាប់លើកសំណើអំពីរបៀបវារៈបែបនេះ ។ ក្រុមសំណួរដំបូង ផ្តោតលើការសម្រួចអាទិភាពនានាស្តីពីគោលដៅយុទ្ធសាស្ត្រ ចំពោះអភិបាលកិច្ចធនធានធម្មជាតិ ។ ក្រុមសំណួរបន្ទាប់ ផ្តោតលើបញ្ហាប្រឈមនានានៃការអនុវត្តលើការអភិវឌ្ឍស្ថាប័ន ដើម្បីសម្រេចបាននូវការកែលម្អអភិបាលកិច្ចលើធនធានធម្មជាតិ ។

## ការសម្រួចអាទិភាពៈ ជម្រើសដែលមានលក្ខណៈជាយុទ្ធសាស្ត្រចំពោះអភិបាលកិច្ចធនធានធម្មជាតិ

ធនាគារពិភពលោកបានសរសេរក្នុងរបាយការណ៍ពេញលេញមួយរបស់ខ្លួន ទៅកាន់ក្រុមពិគ្រោះយោបល់នៃម្ចាស់ជំនួយកាលពីប្រាំមួយឆ្នាំមុនអំពី “កម្ពុជាស្ថិតនៅត្រង់ផ្លូវបំបែក” ។ “ធនធានធម្មជាតិ” ថ្វីត្បិតតែនៅសម្បូណ៌នៅឡើយក្តី កំពុងស្ថិតនៅក្រោមសម្ពាធកាន់តែខ្លាំងឡើងៗ ។ គោលនយោបាយគ្រប់គ្រងធនធានធម្មជាតិបច្ចុប្បន្ន បន្ថែមលើការធ្វើឱ្យប៉ះពាល់ដល់អវិជ្ជមានចំពោះកត្តាលើកទឹកចិត្តនានា ចំពោះកំណែទម្រង់អភិបាលកិច្ចទូទៅ ដែលមានចែងនៅក្នុងយុទ្ធសាស្ត្រចតុកោណ ទំនងជាធ្វើឱ្យកើនឡើងនូវការប្រជែងដណ្តើមធនធានធម្មជាតិ ពីការកើនឡើងនៃចំនួនប្រជាជន... ការប្តូរទិសដៅអភិបាលកិច្ចនៃធនធានធម្មជាតិ អាចលើកកម្ពស់ជីវភាពរស់នៅៗតំបន់ជនបទ ហេតុនេះកាត់បន្ថយសក្តានុពលនៃការកើតមានទំនាស់ រួមចំណែកកាន់តែច្រើនឡើងចំពោះកំណើនសេដ្ឋកិច្ច និងការនាំចេញ ផ្តល់សេវាបរិស្ថានកាន់តែបានល្អប្រសើរ និងបង្កើនប្រាក់ចំណូលសាធារណៈ” (World Bank 2004b: 71) ។

ហានិភ័យដែលធនាគារពិភពលោក បានគូសបញ្ជាក់នៅក្នុងរបាយការណ៍គោលនេះ ទើបកើនឡើងជាខ្លាំងក្នុងចន្លោះឆ្នាំទាំងនោះ ។ គេឃើញមានការរីកចម្រើនគួរឱ្យកត់សំគាល់អំពីគោលនយោបាយស្តីពីធនធានធម្មជាតិ ចាប់តាំងពីពេលនោះមក ជាអាទិ៍ ការព្យួរ ឬការដកយកសម្បទានព្រៃពាណិជ្ជកម្មស្ទើរតែទាំងអស់ និងការអនុម័តបទបញ្ញត្តិ ដើម្បីគាំទ្រសហគមន៍ជលផល និងសហគមន៍ព្រៃឈើ ក៏ដូចជាគំនិតផ្តួចផ្តើមមួយចំនួន ក្នុងការបង្កើនការផ្តល់កម្មសិទ្ធិដីធ្លីនៅជនបទ និងកសាងសមត្ថភាពដើម្បីដោះស្រាយវិវាទដីធ្លី ។ ប៉ុន្តែកន្លងមក អត្ថប្រយោជន៍នៃវិធានការទាំងនេះ មានតិចតួចធៀបនឹងហានិភ័យថ្មីៗ ដែលសហគមន៍ជនបទប្រឈមមុខ ។

បញ្ហាទំនាស់អំពីសិទ្ធិដីធ្លី ដែលរួមមានទាំងដីកសិកម្ម និងដីព្រៃ តួយ៉ាងដូចជាកសិករក្រីក្របំផុត និងសហគមន៍ពឹងផ្អែកលើព្រៃឈើ មានទំនាស់ជាមួយផ្នែកឯកជនដែលមានទំនាក់ទំនងផ្នែកនយោបាយ យោធា និង/ឬស្ថាប័ននានា

របស់រដ្ឋ ។ យោងតាមអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (ឆ្នាំ២០០៥) ដោយមានបំណងជម្រុញការអភិវឌ្ឍកសិ-ឧស្សាហកម្ម "វិធីសាស្ត្រដែលមានអាទិភាពសំរាប់ផ្តល់សម្បទានដីសេដ្ឋកិច្ច គឺតាមរយៈសំណើដែលមានលក្ខណៈប្រកួតប្រជែង" ។ ប្រការនេះបង្ហាញថា ចាំបាច់ត្រូវមានអភិក្រមកសាងផែនការតំបន់រួមមួយ ដើម្បីកំណត់តំបន់សម្រាប់អភិវឌ្ឍន៍សក្តានុពលដែលត្រូវដាក់សំណើ ។ ទោះជាយ៉ាងណាក្តី ក្នុងការអនុវត្តជាក់ស្តែង សំណើទាំងនេះត្រូវបានបែងចែកសម្រាប់តែសំណើដែលគ្មានការស្នើសុំ ។ ប្រការនេះត្រូវបានច្បាប់អនុញ្ញាត "ដែលអ្នកស្នើសុំ... គប្បីសន្យាអំពីផលប្រយោជន៍ដ៏ច្រើនលើសលុប" ។ ទោះជាយ៉ាងណាក្តី ការលើកលែង បានក្លាយទៅជានិយាមទៅហើយ ។ ស្តីពីសម្បទានចំពោះសកម្មភាពរ៉ែ និងការរុករករ៉ែ ក្របខ័ណ្ឌគតិយុត្ត រឹតតែមានលក្ខខណ្ឌកំណត់មិនច្បាស់លាស់ ។

ចំណុចត្រួតគ្នាលើតំបន់ដែលបានកំណត់សម្រាប់សម្បទានដីសេដ្ឋកិច្ច សម្បទានរ៉ែ តំបន់ព្រៃឈើគ្រប់គ្រងដោយសហគមន៍ និងដីកសិកម្មតូចៗ កំពុងជម្រុញឱ្យមានការតតាំង បាតុកម្ម និងទំនាស់នៅមូលដ្ឋានសាជាថ្មី ។ យោងតាមរបាយការណ៍សារព័ត៌មានកាលពីពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានធ្វើការសន្យាជាថ្មីចំពោះរដ្ឋាភិបាលបរទេស និងវិនិយោគិន ចំពោះដីកសិកម្មដែលមានផ្ទៃក្រឡាធំៗ ហើយការសន្យានោះទំនងជាមានទំហំលើសពីផ្ទៃដីសរុបដែលមាន ។ ក្រុមរៀបចំសហគមន៍ និងក្រុមសង្គមស៊ីវិលដែលបានការពារសិទ្ធិប្រើប្រាស់ធនធានសម្រាប់ប្រជាជនមូលដ្ឋានបានបរាជ័យជាហូរហែរ ក្នុងការសម្រេចបាននូវដំណោះស្រាយតាមរយៈតុលាការ ហើយពណ៌នាអំពីបរិយាកាសនិទណ្ឌភាព និងភាពលំអៀងដែលមានលក្ខណៈជាប្រព័ន្ធ ចំពោះអ្នកក្រីក្រប្រើប្រាស់ធនធាន ក្រុមជនជាតិដើមភាគតិច និងសហគមន៍មូលដ្ឋានដទៃទៀត (IPNN 2010; Ratner and Parnell 2011) ។

ដូចគ្នាដែរនៅក្នុងវិស័យជលផល ទោះបីជាមានការផ្លាស់ប្តូរគោលនយោបាយយ៉ាងច្រើន ដែលកាត់បន្ថយផ្ទៃដីសម្បទានពាណិជ្ជកម្ម ក្នុងការផ្តល់លទ្ធភាពប្រើប្រាស់ដល់សហគមន៍នៅឆ្នាំ២០០០/២០០១ ទំនាស់រវាងអ្នកនេសាទបែបពាណិជ្ជកម្ម និងអ្នកនេសាទចិញ្ចឹមក្រពះ នៅតែកើតមានទន្ទឹមគ្នានឹងបញ្ហាប្រឈមមុខថ្មីៗ រួមមាន ការប្រជែងប្រើប្រាស់ទឹក និងដី នៅក្នុងតំបន់វាលទំនាប និងផលប៉ះពាល់ដែលអាចកើតមាននៃហេដ្ឋារចនាសម្ព័ន្ធថ្មី ជាពិសេសទំនប់ទឹក (So *et al.*, 2010 ) ។ គ្មានក្របខ័ណ្ឌដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបានបង្កើតឡើងដើម្បីប៉ាន់ស្មានអំពីផលប៉ះពាល់ផ្នែកបរិស្ថានជាបន្តបន្ទាប់ និងផលប៉ះពាល់ផ្នែកសង្គមនៃគម្រោងថ្មីៗឡើយ រាប់ទាំងគម្រោងថាមពលវារីអគ្គិសនី ប្រព័ន្ធស្រោចស្រព និងប្រតិបត្តិការរ៉ែ ហើយក៏គ្មានការថ្លឹងថ្លែងចំណុចទាំងអស់នេះប្រកបដោយលក្ខណៈសត្យានុម័តជាមួយនឹងផលប្រយោជន៍រំពឹងទុកនោះទេ ។ នីតិវិធីវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គម ហាក់ដូចជាមិនយកចិត្តទុកដាក់ចំពោះផលប៉ះពាល់ជាបន្តបន្ទាប់ មកលើសេវាបរិស្ថានឡើយ ដូចជាការថែរក្សាជំរកត្រី និងផ្លូវធ្វើដំណើររបស់ត្រីតាមផ្លូវទឹក និងកន្លែងតភ្ជាប់តាមវាលទំនាប ក៏ដូចជាផលប៉ះពាល់ផ្នែកសង្គម និងសេដ្ឋកិច្ច ចំពោះសហគមន៍នានាលើសពីតំបន់អនុវត្តគម្រោងផ្ទាល់ (Nguyen-Khoa and Puthy 2006 ) ។

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកអភិបាលកិច្ចល្អជាស្នូល ហើយគូសបញ្ជាក់វិស័យកសិកម្ម (រាប់ទាំងព្រៃឈើ និងជលផល) ថាជា "ចតុកោណកំណើនយុទ្ធសាស្ត្រ" ទីមួយ ក្នុងចំណោមចតុកោណកំណើនយុទ្ធសាស្ត្របួនដែលតម្រូវឱ្យមានការគាំទ្រជាអាទិភាព (រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០០៨) ។ ចំណុចនេះជាចំណុចត្រឹមត្រូវទាំងស្រុង ហើយផ្តល់នូវចំណុចយោងសមស្របមួយ សំរាប់ពិភាក្សាអំពីជំរើសគោលនយោបាយដែលមានលក្ខណៈជាយុទ្ធសាស្ត្រសំរាប់អនាគត ។ ប៉ុន្តែ ទោះជាមានទិសដៅគោលនយោបាយរួមបែបនេះក្តី ការប្រកួតប្រជែង និងទំនាស់ដែលកើតចេញពីការប្រើប្រាស់ធនធានធម្មជាតិបច្ចុប្បន្ន និងផែនការប្រើប្រាស់ធនធានធម្មជាតិ បង្ហាញតម្រូវការឱ្យមានឋានានុក្រមច្បាស់លាស់ នូវគោលដៅអភិបាលកិច្ចធនធានធម្មជាតិ ក្នុងទំនាក់ទំនងជាមួយកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង ពិពិធកម្មចំពោះការចិញ្ចឹមជីវិត សមធម៌ ស្ថិរភាពសង្គម និងសុខុមាលភាពសហគមន៍ ។ ការពិភាក្សាអំពីគោលនយោបាយនៅក្នុងក្របខ័ណ្ឌនេះ អាចគាំទ្រដោយការស្រាវជ្រាវផ្អែកលើភស្តុតាង ដែលមានគោលដៅគូសបញ្ជាក់ទិដ្ឋភាពអភិវឌ្ឍន៍តាមបែបផ្សេង និងផលប៉ះពាល់នៃការអភិវឌ្ឍទាំងនោះទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួន ឬគោលដៅនានា ដូចចំណុចដែលបានលើកឡើងខាងលើដោយទាញចេញនូវការ

វិភាគអំពីនិន្នាការអភិវឌ្ឍន៍ និងបទពិសោធន៍នៅកម្ពុជា ក៏ដូចជានៅប្រទេសកំពុងអភិវឌ្ឍដទៃទៀត និងក្នុងតំបន់នានា ។ អាទិភាពស្រាវជ្រាវរួមមាន៖

ក) តើអ្វីខ្លះជាគុណសម្បត្តិនៃ*សម្បទានសេដ្ឋកិច្ចទ្រង់ទ្រាយធំ ធៀបនឹងប្រព័ន្ធផលិតកម្មកសិកម្មខ្នាតតូច* ជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចជនបទ? តើមានហានិភ័យអ្វីខ្លះអំពីសមធម៌ សន្តិសុខស្បៀង ស្ថិរភាពសង្គម និងសុខុមាលភាពសហគមន៍? តើអ្វីជាបទពិសោធន៍ល្អប្រសើរក្នុងការវិនិយោគកសិ-ឧស្សាហកម្មអន្តរជាតិ ដែលបានបង្ហាញថាមានប្រសិទ្ធភាពបំផុត ដើម្បីធានាឱ្យមានការបែងចែកផលប្រយោជន៍ប្រកបដោយសមធម៌ចំពោះផលិតករក្នុងស្រុក និងការពារសិទ្ធិរបស់ពួកគេ? តើកត្តាអ្វីខ្លះដែលកំណត់ជោគជ័យនៃគំរូវិនិយោគកសិកម្ម ដូចជាការធ្វើកសិកម្មផ្អែកលើកិច្ចសន្យា ដែលបង្កើនលទ្ធភាពបានទទួលបច្ចេកវិទ្យា និងទីផ្សារ ហើយរក្សាបាននូវកម្មសិទ្ធិដីធ្លីតូចៗ?

ខ) តើ*ធនធានព្រៃឈើ និងជលផល* ដែលជាសម្បត្តិរួមរបស់កម្ពុជា អាចធ្វើជាសំណាញ់សុវត្ថិភាពសង្គម ក្បាលម៉ាស៊ីនសម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ឬប្រភពនៃប្រាក់ចំណូលរបស់រាជរដ្ឋាភិបាលបានកំរិតណា? នៅក្នុងកាលៈទេសៈណាខ្លះ ដែលគោលដៅទាំងនេះប្រជែងគ្នា ហើយតើគោលដៅទាំងនោះ អាចសម្របសម្រួលជាមួយគ្នាយ៉ាងដូចម្តេច?

គ) តើវិធីសំខាន់បំផុតអ្វីខ្លះ ដែល*ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ* (ពិសេសទំនប់ទឹក ផ្លូវថ្នល់ និងប្រព័ន្ធធារាសាស្ត្រ) អាចធ្វើឱ្យខូចខាតដល់សេវាផ្នែកបរិស្ថាន? តើចំណុចនេះមានន័យយ៉ាងណាចំពោះការទ្រាំទ្រ និងសមត្ថភាពនៅកំរិតមូលដ្ឋាន ក្នុងការបន្សាំជាមួយនឹងការប្រែប្រួលធាតុអាកាស និងនិន្នាការដទៃទៀត ដែលទំនងជាប៉ះពាល់ដល់សន្តិសុខស្បៀង? តើផលប៉ះពាល់ជាបន្តបន្ទាប់ទាំងនេះ ត្រូវបានវាស់ស្ទង់យ៉ាងដូចម្តេច ចំពោះផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និងផលប្រយោជន៍សង្គមដែលបានរំពឹងទុក? តើតម្រូវការប្រជែងគ្នាទាំងនេះត្រូវបានសម្រុះសម្រួលគ្នាតាមវិធីណា ដើម្បីឱ្យមានប្រសិទ្ធភាព?

ឃ) តើអ្វីខ្លះអាចជាផលប្រយោជន៍ និងហានិភ័យនៃវិនិយោគក្នុងពេលអនាគតលើ *ឧស្សាហកម្មនីស្សារណកម្ម* ពិសេសប្រេងឥន្ធនៈនិងរ៉ែ? តើផលប្រយោជន៍ និងហានិភ័យទាំងនេះទំនងជាត្រូវបានបែងចែកយ៉ាងដូចម្តេច រវាងក្រុមសង្គមនានា? តើផលប្រយោជន៍ និងហានិភ័យទាំងនោះមានផលប៉ះពាល់យ៉ាងដូចម្តេច មកលើឱកាសចិញ្ចឹមជីវិត និងនិន្នាការអភិវឌ្ឍន៍លើវិស័យកសិកម្ម ព្រៃឈើ និងជលផល? តើបទពិសោធន៍អន្តរជាតិល្អប្រសើរអ្វីខ្លះមានលក្ខណៈសមស្រប ដើម្បីណែនាំដល់ការសម្រេចចិត្តទាក់ទងនឹងវិនិយោគទាំងនេះ និងការគ្រប់គ្រងផលចំណូលពីធនធាន និងប្រាក់ចំណូលបានមកពីសកម្មភាពទាំងនេះ?

## ការលើកកម្ពស់ប្រសិទ្ធភាព៖ អភិវឌ្ឍន៍ស្ថាប័ន និងកំណែទម្រង់អភិបាលកិច្ច

ការលើកកម្ពស់អភិបាលកិច្ចធនធានធម្មជាតិ តម្រូវឱ្យមានកត្តានានាជាច្រើនទៀត បន្ថែមលើគោលនយោបាយតាមវិស័យ និងបទបញ្ញត្តិត្រឹមត្រូវ ។ កិច្ចការនេះពឹងផ្អែកយ៉ាងសំខាន់លើកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាពនៃស្ថាប័ននានារបស់រដ្ឋ ស្របគ្នាជាមួយនឹងវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីជួយប្រែក្លាយគោលដៅគោលនយោបាយឱ្យទៅជាការអនុវត្តជាក់ស្តែង ។ ប្រការនោះមានន័យថា ត្រូវមានវិធានការដើម្បីធ្វើយ៉ាងណាយធានាបាននូវ៖

- *ភាពជាតំណាង* មានការរាប់បញ្ចូលនៃក្រុមរងផលប៉ះពាល់ ជាពិសេសប្រជាជនក្រីក្រ និងប្រជាជនងាយរងគ្រោះក្នុងការរៀបចំគោលនយោបាយ និងកសាងផែនការអភិវឌ្ឍន៍នៅគ្រប់កំរិត

- *ការបែងចែកសមត្ថកិច្ច* សមស្របរវាងរដ្ឋ ឯកជន និងតួអង្គសង្គមស៊ីវិលនានា អំពីការសម្រេចចិត្តចំពោះការបែងចែក និងការគ្រប់គ្រងធនធានធម្មជាតិនិង

- យន្តការរឹងមាំនៃ*គណនេយ្យភាព* ដើម្បីធ្វើយ៉ាងណាឱ្យបុគ្គល និងក្រុមនានា ដែលមានសមត្ថកិច្ចក្នុងការសម្រេចចិត្ត ទទួលខុសត្រូវចំពោះផលវិបាកសាធារណៈ បណ្ដាលមកពីការជ្រើសរើសរបស់ពួកគេ ។

ឧទាហរណ៍ ទំនាស់ដីធ្លី គឺជាកង្វល់ចំបងបំផុតក្នុងពេលបច្ចុប្បន្ន ចំពោះជនជាតិដើមភាគតិចនៅកម្ពុជា (IPNN 2010) ។ របាយការណ៍កាលពីពេលថ្មីៗរបស់បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលស្ដីពីជនជាតិដើមភាគតិចបញ្ជាក់ថា ដោយសារមានការគំរាមកំហែងពីសម្បទានសេដ្ឋកិច្ច សម្បទានរ៉ែ និងគម្រោងវារីអគ្គិសនី "ស្ថានភាពស្ដីពីសុវត្ថិភាពដីធ្លីរបស់ជនជាតិដើមភាគតិចបានចុះថយ... វិវាទជុំវិញអសុវត្ថិភាពនៃកម្មសិទ្ធដីធ្លី ចំពោះជនជាតិដើមភាគតិច គ្រាន់តែជាការបង្ហាញអំពីភាពធ្ងន់ធ្ងរនៃស្ថានភាពទូទៅតែប៉ុណ្ណោះ ហើយប្រសិនបើមានគម្រោងមួយចំនួនតូចនៃគម្រោងទាំងនេះបន្តអនុវត្ត ប្រការនេះអាចរួមចំណែកដល់អស្ថិរភាពបរិស្ថាន សង្គម និងសេដ្ឋកិច្ចនៅក្នុងប្រទេស" (IPNN 2010: 5) ។ ទោះបីជាយ៉ាងណាក្ដី តម្រូវការធំបំផុតរបស់ពួកគេពុំមែនជាការកែប្រែគោលនយោបាយ ឬច្បាប់ឡើយ ។ ពួកគេកំពុងស្វែងរកការអនុវត្តប្រកបដោយយុត្តិធម៌នូវច្បាប់ភូមិបាលនៅជាធរមាន ដែលការការពារសិទ្ធរបស់ជនជាតិដើមភាគតិចចំពោះទឹកដីដែលពួកគេបានប្រើប្រាស់ និងរស់នៅតាមបែបប្រពៃណី ទោះបីជាទាំងអស់នេះ មិនត្រូវបានគេយកចិត្តទុកដាក់ដោះស្រាយក្នុងការអនុវត្តជាក់ស្ដែងក្ដី ។ ពួកគេកំពុងស្វែងរកគណនេយ្យភាពរបស់តុលាការ អាជ្ញាធរសាធារណៈ និងកងទ័ព ចំពោះការគោរពច្បាប់ និងការចូលរួមពេញលេញក្នុងការសម្រេចចិត្តអំពីបញ្ហានានាដែលប៉ះពាល់ដល់ការចិញ្ចឹមជីវិតរបស់ពួកគេ ។

ម្ចាស់ជំនួយបានវិនិយោគយ៉ាងច្រើនលើទំនើបភាវូបនីយកម្មនៃវិស័យតុលាការរបស់កម្ពុជា ប៉ុន្តែតុលាការបន្តខ្វះឯករាជ្យភាព ភាពស្របច្បាប់ និងសមត្ថភាព ដើម្បីដោះស្រាយវិវាទប្រកបដោយប្រសិទ្ធភាព ចំពោះដីធ្លី និងធនធានធម្មជាតិដទៃទៀត ។ ប្រាកដណាស់ ការសិក្សាមួយអំពីវិវាទដីធ្លីបានរកឃើញថាមិនមាន "ច្បាប់ជាលាយល័ក្ខអក្សរដំណើរការផ្លូវច្បាប់ ឬទម្រង់នៃការសម្រេចចិត្តផ្អែកលើវិធាននៃច្បាប់ឡើយ ក្នុងន័យដែលថា វិធានទាំងនោះមានមុខងារតិចតួចក្នុងដំណើរការដោះស្រាយវិវាទ" (Adler et al 2006: 39) ។ ផ្ទុយទៅវិញ លទ្ធផលក្នុងការដោះស្រាយវិវាទដីធ្លី មានប្រភពមកពីសម្ពាធនយោបាយ ចំពោះអ្នកធ្វើគោលនយោបាយសំខាន់ៗ ធ្វើឱ្យអ្នកនិពន្ធសន្និដ្ឋានថានៅក្នុងបរិបទនៃអភិបាលកិច្ចបច្ចុប្បន្នការកៀងគរផ្នែកនយោបាយក្នុងការការពារសិទ្ធិដីធ្លីនៅមូលដ្ឋាន នៅតែមានលក្ខណៈជាសារវន្ត ដើម្បីធ្វើឱ្យមានគណនេយ្យភាពកាន់តែខ្ពស់ និងភាពឆ្លើយតបពីតួអង្គរដ្ឋាភិបាល (Adler et al 2006) ។ ការសិក្សាទាក់ទងមួយអះអាងថា កិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់ការគ្រប់គ្រងវិវាទដីធ្លី គប្បីរួមបញ្ចូលនូវការលើកទឹកចិត្តឱ្យមានការចូលរួមពីសង្គមស៊ីវិល តាមរយៈកិច្ចប្រឹងប្រែងបង្កើតថ្មីនូវដំណោះស្រាយវិវាទតាមបែបផ្សេង (Center for Advanced Study 2006) ។ ក្នុងន័យនេះ ការវាយតម្លៃកិច្ចដំណើរការរបស់ស្ថាប័នថ្មី ចំពោះការដោះស្រាយវិវាទដែលបានបង្កើតឡើងស្របគ្នាជាមួយនឹងតុលាការ រួមមានគណៈកម្មការសុរិយោដី និងក្រុមប្រឹក្សាគណនេយ្យភាពថ្នាក់ខេត្ត ចំពោះមូលនិធិឃុំ/ស្រុក ដែលគ្រប់គ្រងដោយកម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ មានសារៈសំខាន់ណាស់ ។

ដូចគ្នាដែរ ចំពោះស្ថាប័នសហគមន៍នេសាទ និងសហគមន៍ព្រៃឈើ ការធានាឱ្យមានការទទួលស្គាល់ស្របច្បាប់អំពីសិទ្ធិក្នុងការទទួលបាន និងគ្រប់គ្រងធនធាននៅមូលដ្ឋាន គឺគ្រាន់តែជាជំហានដំបូងតែប៉ុណ្ណោះ ។ ក្នុងការអនុវត្តជាក់ស្ដែង សមត្ថភាពរបស់សហគមន៍ក្នុងការការពារសិទ្ធរបស់ពួកគេ អាស្រ័យលើភាពឆ្លើយតប និងគណនេយ្យភាពរបស់អាជ្ញាធរសាធារណៈ ។ ការបែងចែកផលប្រយោជន៍លើកំរិតដែលថ្នាក់ដឹកនាំស្ថាប័នសហគមន៍ទាំងនេះ ទទួលខុសត្រូវចំពោះសមាជិករបស់ខ្លួន ។ ការពិនិត្យមើលសាឡើងវិញមួយកាលពីពេលថ្មីៗអំពីសហគមន៍នេសាទ និងសហគមន៍ព្រៃឈើបានរកឃើញថា សហគមន៍ទាំងពីរកំពុងបង្ហាញឱ្យឃើញពីការលើកកម្ពស់ក្នុងការការពារធនធាន និងការអនុវត្តច្បាប់ ប៉ុន្តែគ្រួសារក្រីក្រនៅដើរមិនទាន់គេនៅឡើយ ទាក់ទិននឹងសមត្ថភាពក្នុងការទទួលចំណែកផលឱ្យមានសមធម៌ (Blomley *et al.* 2010) ។

ការវិនិយោគលើសកម្មភាពរ៉ែ ប្រេងឥន្ធនៈ និងការផលិតថាមពលវារីអគ្គិសនី ជាគោលការណ៍អាចធ្វើជាប្រភព

ចំណូលរបស់រាជរដ្ឋាភិបាលក្នុងរយៈពេលវែងដែលអាចផ្តល់ហិរញ្ញប្បទាន ចំពោះសម្បត្តិសាធារណៈ តាមរយៈកម្មវិធីសុខភាពសាធារណៈ អប់រំ និងការការពារបរិស្ថាន ។ ទោះជាយ៉ាងណាក្តី មុនពេលអាចធ្វើដូច្នេះបាន "ចាំបាច់ត្រូវមានការកែលំអច្រើនក្នុងការគ្រប់គ្រងរបស់វិស័យដែលក្នុងពេលបច្ចុប្បន្ន ជាការគ្រប់គ្រងអប្រសិទ្ធភាព និងមិនច្បាស់លាស់" (World Bank and IFC 2009: xiii ) ។ បន្ថែមលើការបញ្ជាក់អំពីក្របខ័ណ្ឌច្បាប់ និងគតិយុត្ត ចាំបាច់ត្រូវមានវិធានការដែលបង្កើនគណនេយ្យភាព និងតម្លាភាពអំពីការប្រមូលចំណូល និងការសម្រេចចិត្តចំពោះការយកប្រាក់ចំណូលនេះទៅបន្តវិនិយោគលើសម្បត្តិសាធារណៈ ។ កម្មវិធីស្តីពីគំនិតផ្តួចផ្តើមអំពីតម្លាភាពនៃឧស្សាហកម្មនិស្សារណកម្ម (EITI ) ផ្តល់ការណែនាំសំខាន់ក្នុងផ្នែកនេះ ដោយកសាងលើកិច្ចប្រតិបត្តិល្អប្រសើរនៅអន្តរជាតិ ។

អាទិភាពនៃការស្រាវជ្រាវ ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការអភិបាលកិច្ច ដែលប៉ះពាល់ដល់ការគ្រប់គ្រងធនធានធម្មជាតិ រួមមាន៖

ក) តើយន្តការអ្វីខ្លះបានបង្ហាញឱ្យឃើញថា មានប្រសិទ្ធភាពបំផុតក្នុងការបង្កលក្ខណៈឱ្យមាន*ភាពជាតំណាងប្រកបដោយសមធម៌* នៃប្រជាជនក្រីក្រ និងក្រុមពលរដ្ឋងាយរងគ្រោះ ក្នុងការសម្រេចចិត្តចំពោះកំណែទម្រង់គោលនយោបាយ និងស្ថាប័ន ក្នុងវិស័យធនធានធម្មជាតិ? តើមេរៀនអ្វីខ្លះបានពីបទពិសោធន៍អន្តរជាតិ ដែលអាចជួយពន្លឿនការដាក់បញ្ចូលអភិបាលកិច្ចធនធានធម្មជាតិទៅក្នុងសង្គមនៅកម្ពុជាផ្អែកលើស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច និងនយោបាយបច្ចុប្បន្ន?

ខ) តើយន្តការអ្វីខ្លះរួមទាំងយន្តការផ្លូវការ និងក្រៅផ្លូវការ ដែលមានលទ្ធភាពខ្ពស់បំផុតក្នុងការប្រឹងប្រែងលើកកម្ពស់*គណនេយ្យភាពសាធារណៈ* របស់អ្នកសម្រេចចិត្តនៅថ្នាក់ឃុំ ស្រុក ខេត្ត និងថ្នាក់ជាតិ ចំពោះសេចក្តីសម្រេចចិត្តនានាអំពីការបែងចែក និងគ្រប់គ្រងធនធានធម្មជាតិ? តើបណ្តាញ និងស្ថាប័នផ្សេងៗនៃសហគមន៍មូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយ មានមុខងារអ្វីខ្លះចំពោះបញ្ហានេះ ហើយតើមុខងារទាំងនោះត្រូវបានពង្រឹងយ៉ាងដូចម្តេច?

គ) តើយុទ្ធសាស្ត្រអ្វីខ្លះដែលមានប្រសិទ្ធភាពបំផុតក្នុងការកសាងស្ថាប័ន ដើម្បីឱ្យមាន *ដំណោះស្រាយវិវាទ និងយុត្តិធម៌* ចំពោះប្រជាជនក្រីក្រដែលប្រើប្រាស់ធនធានធម្មជាតិ? តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ចំណងទាក់ទងរវាងតុលាការ រចនាសម្ព័ន្ធរដ្ឋបាល និងដំណើរការដោះស្រាយវិវាទក្រៅផ្លូវការ ដំណើរការដោះស្រាយវិវាទតាមបែបផ្សេង? តើមានមេរៀនអ្វីខ្លះអំពីបទពិសោធន៍អន្តរជាតិស្តីពីការផ្តោតជាសំខាន់ និងលំដាប់លំដោយនៃការវិនិយោគនៅក្នុងទិដ្ឋភាពផ្សេងៗនៃដំណោះស្រាយវិវាទ?

ឃ) តើការវិនិយោគអ្វីខ្លះទៅលើ*កិច្ចអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន* មានសារៈសំខាន់បំផុតក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃគំនិតផ្តួចផ្តើមស្តីពីការគ្រប់គ្រងធនធានធម្មជាតិនៅតាមសហគមន៍? តើធ្វើដូចម្តេចដើម្បីឲ្យគំនិតផ្តួចផ្តើមទាំងអស់នេះ អាចដាក់បញ្ចូលឱ្យបានល្អប្រសើរទៅក្នុងប្រព័ន្ធវិមជ្ឈការដែលត្រូវបានពង្រឹងកាលពីពេលថ្មីៗ សម្រាប់កសាងផែនការអភិវឌ្ឍន៍ជនបទ? តើឧបសគ្គអ្វីខ្លះដែលចាំបាច់ត្រូវដោះស្រាយ ដើម្បីឱ្យគ្រួសារក្រីក្រ និងគ្រួសារងាយរងគ្រោះ បានទទួលលំហូរផលប្រយោជន៍កាន់តែល្អប្រសើរ?

ង) តើធ្វើដូចម្តេចដើម្បីលើកកម្ពស់ការ*សម្រេចចិត្តចំពោះការវិនិយោគរបស់វិស័យឯកជន?* តើដំណើរការអ្វីខ្លះដែលមានប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់ការប៉ាន់ប្រមាណអំពីគម្រោងនីមួយៗ ទៅកាន់ ការវាយតម្លៃបែបយុទ្ធសាស្ត្រអំពីផលប្រយោជន៍ និងហានិភ័យដែលមានលក្ខណៈទូលាយ? តើយុទ្ធសាស្ត្រណាខ្លះ ដែលមានលទ្ធភាពខ្ពស់បំផុតក្នុងការជំរុញអនុម័ត និងអនុវត្តន៍ស្តង់ដារ និងកិច្ចប្រតិបត្តិល្អប្រសើរអន្តរជាតិ តាមវិស័យជាក់លាក់ ដើម្បីណែនាំដល់ការវិនិយោគ ផ្នែកកសិ-ឧស្សាហកម្ម រ៉ែ ហេដ្ឋារចនាសម្ព័ន្ធ និងថាមពល?

## សេចក្តីសន្និដ្ឋាន

អត្ថបទខ្លីនេះ បានគូសបញ្ជាក់អំពីមុខងារសំខាន់ៗនៃអភិបាលកិច្ចធនធានធម្មជាតិ ចំពោះលទ្ធភាពអភិវឌ្ឍន៍របស់កម្ពុជា ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀងប្រកបដោយចីរភាព ។ អត្ថបទនេះក៏បានបង្ហាញផងដែរនូវបញ្ហាប្រឈមមួយចំនួន ដើម្បីលើកកម្ពស់អភិបាលកិច្ចធនធានធម្មជាតិ ក្នុងកំរិតគោលដៅយុទ្ធសាស្ត្រ ក៏ដូចជាសមត្ថភាព និងដំណើការនានាផ្នែកស្ថាប័នផងដែរ ។ អត្ថបទនេះមានបំណងលើកឡើងនូវចំណុចមូលដ្ឋានសម្រាប់ពិភាក្សា ពុំមែនដើម្បីផ្តល់ចម្លើយជាក់លាក់នោះទេ ប៉ុន្តែដើម្បីផ្តោតការយកចិត្តទុកដាក់លើបញ្ហាសំខាន់ៗដែលអាចបង្កើតជាមូលដ្ឋាននៃរបៀបវារៈបែបសហការ ដើម្បីឱ្យមានកិច្ចពិភាក្សា និងស្រាវជ្រាវផ្នែកគោលនយោបាយ ។